# បទបញ្ជារបស់មន្ត្រីសុខាភិបាលក្នុងស្រុកប្រចាំតំបន់ KING COUNTY៖ ការបញ្ជាក់ថាបានចាក់វ៉ាក់សាំង

តំបន់ King County បានបន្តមានករណីកើតជំងឺ COVID-19 និងឈឺចូលមន្ទីរពេទ្យក្នុងកម្រិតខ្ពស់ និងមានកំណើនអត្រាស្លាប់កាន់តែច្រើនដោយសារមេរោគបំលែងខ្លួនថ្មីដែលតា (Delta) ។ ករណីទាំងនេះនិងការស្លាប់អាចជៀសផុតបានប្រសិនបើអ្នកបានចាក់វ៉ាក់សាំងការពារ។ ដូច្នេះហើយ មន្ត្រីសុខភាពនៃក្រសួងសុខាភិបាលសាធារណៈប្រចាំក្រុង Seattle និងតំបន់ King County វេជ្ជបណ្ឌិត Jeff Duchin បានចេញបទបញ្ជាដើម្បីការពារសុខភាព តម្រូវឱ្យមានការបញ្ជាក់ថា បានចាក់វ៉ាក់សាំងគ្រប់ចំនួនឬធ្វើតេស្ត COVID-19 អវិជ្ជមាន មុននឹងអាចចូលរួមក្នុងព្រឹត្តិការណ៍និងគ្រឹះស្ថានទាំងនៅខាងក្នុងអគារនិងនៅខាងក្រៅអគារ។ ការចាក់វ៉ាក់សាំងគឺជាវិធីសាស្ត្រដ៏ល្អបំផុតដើម្បីប្រឆាំងនឹងជំងឺ COVID-19 ។

## គោលការណ៍ថ្មីនេះ រួមមានដូចខាងក្រោម:

### ចាប់ពីថ្ងៃទី ២៥ ខែតុលា ឆ្នាំ២០២១ អតិថិជននឹងតម្រូវឱ្យបង្ហាញភស្តុតាងចាក់វ៉ាក់សាំង COVID-19 ដែលអនុម័តដោយ FDA ឬ WHO នៅតាម៖

- **ព្រឹត្តិការណ៍នៅខាងក្រៅ** ដែលមានមនុស្សចាប់ពី ៥០០ នាក់ឡើងទៅ (ដូចជាព្រឹត្តិការណ៍កីឡាលេងដោយអ្នកអាជីពនិងនិងព្រឹត្តិការណ៍កីឡាលេងដោយនិសិត្សមកពីមហាវិទ្យាល័យ និងព្រឹត្តិការណ៍កម្សាន្តនានាទៀត)
- **ព្រឹត្តិការណ៍កំសាន្តឬគ្រឹះស្ថាននៅខាងក្នុងអគារ** ដោយមិនគិតពីចំនួនមនុស្សឡើយ (ដូចជាព្រឹត្តិការណ៍កីឡាលេងដោយអ្នកអាជីពនិងនិងព្រឹត្តិការណ៍កីឡាលេងដោយនិសិត្សមកពីមហាវិទ្យាល័យ, កន្លែងសម្តែងសិល្បៈនិងកន្លែងសម្តែងតន្ត្រី, រោងភាពយន្ត, កន្លែងហាត់ប្រាណ, និងកន្លែងធ្វើសន្និសិទ/សន្និបាត)
- **ភោជនីយដ្ឋាននិងបារ។** នេះសំដៅទៅលើការទទួលទានអាហារនៅខាងក្នុងអគារ។ វាមិនសំដៅទៅលើទីកន្លែងទទួលទានអាហារនៅខាងក្រៅ មិនសំដៅទៅលើអតិថិជនដែលទិញអាហារយកទៅខាងក្រៅ ហើយវាមិនសំដៅទៅកន្លែងនៅខាងក្នុងអគារដែលគេមិនយកមកធ្វើជាកន្លែងសម្រាប់ទទួលទានអាហារទេមានដូចជាហាងលក់គ្រឿងទេសជាដើម។ បទបញ្ជានេះទុកពេលឱ្យភោជនីយដ្ឋាននិងបារតូចៗដែលអាចដាក់ភ្ញៀវបានត្រឹមតែក្រោម ១២ នាក់រហូតដល់ថ្ងៃទី ៦ ខែធ្នូ ដើម្បីធ្វើការចាប់ផ្តើម។

### អ្វីដែលគេចាត់ទុកថា ជាភស្តុតាងនៃការចាក់វ៉ាក់សាំង?

- កាតចាក់វ៉ាក់សាំង COVID-19 ពីក្រសួង CDC ឬរូបថតនៃកាតចាក់វ៉ាក់សាំងនោះ
- លិខិតបញ្ជាក់ ឬ លេខកូដ QR (QR code) (ចាប់ផ្តើមមាននៅចុងខែកញ្ញា) អាចទាញយកពី MyIRMobile.com (គេហទំព័រមានជាភាសាអង់គ្លេសតែប៉ុណ្ណោះ)
- កាតចាក់វ៉ាក់សាំងជាផ្លូវការផ្សេងៗទៀតមកពីប្រទេសក្រៅឬក្នុងសហរដ្ឋអាមេរិក រួមទាំងកាតចេញពីអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក។ រូបថតឬការថតចម្លងនៃកាតនេះក៏អាចទទួលយកបានដែរ។

**សូមបញ្ជាក់៖**
ក្រដាសបញ្ជាក់ពីពេទ្យឬករណីលើកលែងដោយសារជំនឿសាសនាគឺ**មិនអាច**ទទួលយកបានទេ។
អ្នកមិនចាំបាច់បង្ហាញអត្តសញ្ញាណប័ណ្ណជាមួយភស្តុតាងបញ្ជាក់ចាក់វ៉ាក់សាំងទេ។

## ជម្រើសសម្រាប់អ្នកមិនទាន់បានចាក់វ៉ាក់សាំងឬអ្នកដែលមិនអាចបញ្ជាក់ថាបានចាក់វ៉ាក់សាំង

អ្នកដែលមិនទាន់បានចាក់វ៉ាក់សាំងឬមិនអាចបញ្ជាក់ថាបានចាក់វ៉ាក់សាំង ត្រូវបង្ហាញភស្តុតាងដូចជា៖

- បានធ្វើតេស្ត PCR COVID-19 អវិជ្ជមាន ក្នុងរយៈពេល 72 ម៉ោងកន្លងមក ឬបានទទួលលទ្ធផលធ្វើតេស្តរហ័ស (rapid test) ពីអ្នកធ្វើតេស្តដែលនៅនឹងកន្លែងព្រឹត្តិការណ៍មុនចូលរួម។

គ្រឹះស្ថាននឹងទទួលខុសត្រូវក្នុងការត្រួតពិនិត្យភស្តុតាងចាក់វ៉ាក់សាំងឬលទ្ធផលតេស្តអវិជ្ជមាន។ ក្រសួងសុខាភិបាលសាធារណៈនឹងធ្វើការជាមួយដៃគូរបស់គេដើម្បីផ្តល់ការគាំទ្រផ្នែកបច្ចេកទេសនិងសម្ភារៈអប់រំដល់អាជីវកម្មនិងអង្គការដែលអនុវត្តតាមបទបញ្ជានេះ។

## ការបង្កើតគោលការណ៍ច្បាប់

តំបន់ King County
និងក្រសួងសុខាភិបាលសាធារណៈបានបង្កើតគោលការណ៍ច្បាប់នេះក្រោយពីបានពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាសហគមន៍របស់ក្រសួងសុខាភិបាលសាធារណៈដែលជាអ្នកមើលការខុសត្រូវខាងជំងឺរាតត្បាតនិងការរើសអើងពូជសាសន៍, ជាមួយទីក្រុង, ជាមួយអាជីវកម្មខ្នាតតូច, ជាមួយសភាពាណិជ្ជកម្ម, ជាមួយសហជីពការងារ, ជាមួយសមាគមពាណិជ្ជកម្ម, ក្រុមកីឡាករ, កន្លែងធ្វើព្រឹត្តិការណ៍, ក្រុមសហគមន៍, អ្នកដឹកនាំខាងជំនឿសាសនាទូទាំងតំបន់។
គេមានបំណងធ្វើការងារនេះឱ្យមានដំណើរការល្អ
មានភាពយុត្តិធម៌និងស្មើភាពគ្នាសម្រាប់អាជីវកម្មនិងអ្នករស់នៅក្នុងតំបន់។

**ចំពោះព័ត៌មានបន្ថែម: [kingcounty.gov/verify](kingcounty.gov/verify) (មានអត្ថបទបកប្រែជាភាសាផ្សេងៗទៀត)**